# កម្មវត្ថុព្រះពុទ្ធសាសនា

បើបានសិក្សាពុទ្ធប្រវត្តិឱ្យបានច្បាស់លាស់ត្រឹមត្រូវល្អ ព្រមទាំងត្រិះរិះពិចារណាឱ្យបានដិតដល់លើសកម្មភាពទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធពីការប្រកាសផ្សាយព្រះធម៌ក្នុងដែនជម្ពូទ្វីប តាមរយៈឯកសារនានាមានគម្ពីរព្រះត្រៃបិដកជាពិសេស ទើបយើងដឹងថា កម្មវត្ថុដ៏ចំបងនិងសំខាន់បំផុតដែលត្រូវដោះស្រាយនិងរៀបចំជាបន្ទាន់ក្តៅគគុករបស់ព្រះពុទ្ធសាសនាគឺការកសាងមនុស្ស មិនមែនការកសាងវត្ថុទេ ។ កាលណាមនុស្សមានការចេះដឹង ស្គាល់ខុសត្រូវ ល្អអាក្រក់ បុណ្យបាប គុណទោស មានបញ្ញាភ្លឺថ្លាមិនវង្វេងវង្វាន់ភាន់គំនិត ពេលនោះមនុស្សអាចធ្វើការងារអ្វីៗប្រាកដជាបានសម្រេចផលល្អដូចបំណងប៉ងប្រាថ្នា ។ មុនពុទ្ធកាល ព្រហ្មញ្ញសាសនាបានធ្វើការកៀបសង្កត់យ៉ាងខ្លាំងក្លាដល់មនុស្សដោយប្រកាសផ្សាយថា មនុស្សឋិតនៅក្រោមអំណាចរបស់អាទិទេព ។ មនុស្សពុំមានសមត្ថភាពនឹងបង្កើតសុខដោយខ្លួនឯងបានទេ អ្វីៗទាំងអស់ទាំងអាក្រក់ល្អ សខ្មៅត្រូវឋិតនៅលើកណ្តាប់ដៃអាទិទេពដែលជាអ្នកបង្កើតមនុស្ស ជាអ្នកសម្រេចវាសនាឱ្យមនុស្ស ។ អាទិទេពចង់ឱ្យសុខឬចង់ឱ្យទុក្ខទៅអ្នកណាក៏បាន គឺបើចង់បានសុខកុំឱ្យមានទុក្ខ មនុស្សត្រូវរៀបចំធ្វើការបូជាផ្សេងៗដល់ព្រះអាទិទេព បើគ្រឿងបូជាតូចនឹងបានសុខតូច បើគ្រឿងបូជាធំនឹងបានសុខធំ ហើយបើចង់បានសុខញឹកញាប់ត្រូវរៀបចំធ្វើការបូជាដល់ព្រះអាទិទេពឱ្យបានញឹកញាប់ផងដែរ ។ លក្ខណៈរបស់មនុស្សដែលអង្គុយលើកដៃសំពះបន់ស្រន់ស្វូត្រសុំអង្វរករគេ បញ្ជាក់ឱ្យឃើញនូវភាពចុះចាញ់ ភាពតូចទាប ភាពអន់ថយ ភាពខ្វិលខ្វះសមត្ថភាពទុកខ្លួនត្រឹមតែរស់ដោយសារគេប៉ុណ្ណោះ ។ មនុស្សពុំមានតម្លៃផ្ទាល់របស់ខ្លួនទេ រហូតដល់មើលងាយខ្លួនឯងថា ខ្លួនពុំអាចធ្វើអ្វីបានឡើយក្រៅតែពីអង្គុយសម្លឹងរំពឹងរំពៃសង្ឃឹមផ្ញើវាសនាអនាគតរបស់ខ្លួនទៅលើអ្នកក្រៅខ្លួនវិញមានព្រះអាទិទេពជាដើម ។ បន្ទាប់ពីបានត្រាស់ដឹងធម៌ដែលហៅថាបានសម្រេចសម្មាសម្ពោធិញ្ញាណនោះមក ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសផ្សាយព្រះធម៌យ៉ាងសកម្មដល់ប្រជាជនជម្ពូទ្វីបទាំងមូលឱ្យភ្ញាក់ស្មារតីដែលពីដើមមកពុំមាននរណាធ្លាប់ឮសោះថា មនុស្សជាសត្វខ្ពង់ខ្ពស់និងមានតម្លៃបំផុតគឺគ្មានអ្វីខ្ពស់ជាងមនុស្សនិងគ្មានអ្វីឋិតនៅពីលើមនុស្សទេ ។ សុខទុក្ខ ខ្មៅស ល្អអាក្រក់ បាបបុណ្យ គុណទោសឋិតនៅលើមនុស្សខ្លួនឯងជាអ្នកកសាងនិងជាអ្នកសម្រេចនូវវាសនារបស់ខ្លួន ។ គ្មានទេវតាឥន្ទ្រព្រហ្មយមយក្ខណាមកសម្រេចវាសនារបស់មនុស្សទេ ។ អ្នកណាធ្វើល្អនឹងបានទទួលផលល្អ បើធ្វើអាក្រក់នឹងបានទទួលផលអាក្រក់ចៀសមិនផុតជាដាច់ខាត ។ នេះជាការពិតឥតក្លែងក្លាយ នេះជាធម្មជាតិនៃសេចក្តីសុខទុក្ខរបស់មនុស្ស នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។ រាល់ពេលទេសនា ព្រះពុទ្ធអង្គទ្រង់បានបញ្ជាក់ហើយបញ្ជាក់ទៀតពុំដែលមានភ្លេចមួយវេលាណាឡើយថា ចូរក្រោកឡើងខិតខំធ្វើការងារ

កុំដេកទ្រមក់រង់ចាំផ្ញើវាសនានឹងអ្នកដទៃ ចូរពឹងកម្លាំងខ្លួនឯងប្រសើរជាងពឹងកម្លាំងអ្នកដទៃគឺខ្លួនហ្នឹង ហើយជាទីពឹងរបស់ខ្លួន ។ មនុស្សជាភាវៈដ៏កំពូលប្រសើរក្រៃលែង ព្រោះមនុស្សជាអ្នករចនាវាសនារបស់ខ្លួនឯងផ្ទាល់គឺគ្មានអ្វីដទៃពីមនុស្សនេះទេ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងកោសលជនបទព្រមដោយភិក្ខុសង្ឃច្រើនប្រមាណ៥០០រូប ។ ពេលនោះព្រះមានព្រះភាគទ្រង់សាកសួរមាណពម្នាក់ជាវាសេដ្ឋគោត្រថា ម្នាលវាសេដ្ឋៈ ចុះបណ្ដាពួកព្រាហ្មណ៍ដែលបានសម្រេចត្រៃវិជ្ជា តើមាននរណាមួយទោះបីព្រាហ្មណ៍ម្នាក់ក្ដីដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរឬទេ? វាសេដ្ឋមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការឃើញនូវព្រហ្មនោះមិនមានទេ ។ ម្នាលវាសេដ្ឋៈ ចុះពួកឥសីជាន់មុនៗដែលជាអ្នកតែងមន្ត ជាអ្នករាយមន្តដល់ពួកព្រាហ្មណ៍ ជាអ្នកធ្លាប់បង្រៀនធ្លាប់ស្វាធ្យាយមន្តដល់ពួកព្រាហ្មណ៍ ឥសីទាំងនោះតើមានឥសីណាមួយពោលយ៉ាងនេះនឹងអ្នកថា ព្រហ្មនៅក្នុងទីនេះ ព្រហ្មមានសណ្ឋានយ៉ាងនេះ យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នេះដែរឬទេ? វាសេដ្ឋមាណពក្រាបទូលថា ការស្គាល់ ការឃើញនូវព្រហ្មនោះមិនមានទេ ។

ធម្មទេសនារបស់ព្រះពុទ្ធអង្គត្រង់កន្លែងនេះបញ្ជាក់ថា គ្មានព្រហ្មគ្មានអាទិទេពណានៅពីលើមនុស្សទេ មនុស្សនេះហើយជាម្ចាស់និងជាព្រះព្រហ្មលើខ្លួនឯង ។ រឿងមួយទៀតបានបង្ហាញឱ្យឃើញថា នៅសម័យពុទ្ធកាលប្រជាជនជម្ពូទ្វីបដែលធ្លាប់តែមានជំនឿលើព្រហ្មញ្ញសាសនាជាយូរមកហើយនោះ បាននិយមការត្រាំទឹក ការងូតទឹកនិងការស្រោចស្រប់ដោយទឹកសម្បើមណាស់ព្រោះគេនាំគ្នាជឿទាំងងងិតងងល់ថាអំពើអស់ទាំងនេះអាចលាងជម្រះឱ្យរួចរំដោះចាកនូវឧបទ្រពចង្រៃឬបាបកម្មដែលខ្លួនបានធ្វើរួចមកហើយអំពីមុនបានយ៉ាងស័ក្ដិសិទ្ធិ ។ ព្រះនាងបុណ្ណិកាថេរីជាព្រះភិក្ខុនីដ៏ល្បីល្បាញខាងធម្មទេសនាក្នុងសម័យនោះបានគូសបញ្ជាក់ពន្យល់ដល់ពួកព្រាហ្មណ៍ថា បុគ្គលណាទោះចាស់ក្ដីក្មេងក្ដីធ្វើបាបកម្ម បុគ្គលនោះរមែងរួចចាកបាបកម្មព្រោះការត្រាំទឹកឬការស្រោចស្រប់ដោយទឹកពុំដែលមានទេ បើដូច្នោះកង្កែបហ៊ីង អណ្ដើកកន្ធាយនាគក្រពើឬសត្វដទៃណាមួយដែលតែងហែបហែលអង្កែលអង្កែត្រាច់ចរវាត់ក្នុងទឹកទាំងអស់នឹងទៅឋានសួគ៌ដោយពិត ។ ពួកជនអ្នកសម្លាប់ទ្រាយ អ្នកសម្លាប់ជ្រូក អ្នកនេសាទត្រី អ្នកចាប់ម្រឹគ ពួកចោរ ពួកពេជ្ឈឃាតឬពួកជនឯទៀតដែលមានកម្មដ៏លាមក ពួកជនទាំងនោះក៏អាចរួចចាកបាបកម្មព្រោះការស្រោចស្រប់ដោយទឹកបានដែរ ។ ប្រសិនបើទន្លេគង្គានិងស្ទឹងឯទៀតអាចបន្សាត់បង់ចោលនូវបាបដែលអ្នកធ្វើក្នុងកាលមុនបាន ទន្លេគង្គានិងស្ទឹងទាំងនោះក៏អាចបន្សាត់បង់ចោលនូវបុណ្យរបស់អ្នកបានដែរ ។ ម្នាលព្រាហ្មណ៍! បើអ្នកខ្លាចចំពោះបាបកម្មណា ចូរអ្នកកុំធ្វើនូវបាបកម្មនោះវិញប្រសើរជាង ។ ចូរអ្នកកុំចុះត្រាំទឹកទាំងព្រឹកព្រហាមនាំឱ្យរងានិងនាំឱ្យបៀតបៀនសម្បុរសរីរៈរបស់អ្នកឡើយ ព្រោះអំពើកុហកបោកប្រាស់អស់ទាំងនេះ វាពុំបានផ្ដល់ផលប្រយោជន៍អ្វីបន្តិចសោះឡើយ ។ ធម្មទេសនាប្រកបដោយហេតុផល

ដ៏ល្អឥតខ្ចោះរបស់ព្រះនាងបុណ្ណិកាថេរីជាភិក្ខុនីសង្ឃអង្គអរហន្តនេះបញ្ជាក់ថា បុគ្គលមិនត្រូវលះបង់ខ្លួនចោលឡើយហើយធ្វើវិនាសនារបស់ខ្លួនទៅលើអ្នកដទៃ អ្នកណាធ្វើបាបដោយខ្លួនឯងអ្នកនោះនឹងសៅហ្មងដោយខ្លួនឯង អ្នកណាមិនធ្វើបាបដោយខ្លួនឯងអ្នកនោះនឹងបរិសុទ្ធស្អាតដោយខ្លួនឯង សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធជារបស់ចំពោះខ្លួន អ្នកដទៃនឹងញុាំងអ្នកដទៃឱ្យបរិសុទ្ធមិនបានឡើយ បុគ្គលសាបព្រោះពូជយ៉ាងណារមែងបានទទួលផលយ៉ាងនោះ អ្នកធ្វើហេតុល្អតែងបានទទួលផលល្អ អ្នកធ្វើហេតុអាក្រក់តែងបានទទួលផលអាក្រក់ ។

ដើម្បីឱ្យបានសម្រេចគោលដៅរបស់ព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធទ្រង់បានរៀបចំកម្មវិធីផ្សាយព្រះធម៌ដល់មនុស្សមុនអ្វីៗទាំងអស់ក្នុងគោលបំណងឱ្យមនុស្សក្លាយជាមនុស្សល្អប្រសើរឧត្តមថ្លៃថ្នូររហូតបានដល់ជាមនុស្សពិសេសទៀតផង ។ ចាប់ពីបានត្រាស់ដឹងរហូតដល់បរិនិព្វាន ព្រះសម្មាសម្ពុទ្ធទ្រង់ពុំបានធ្វើអ្វីក្រៅពីធម្មទាននេះទេ ព្រោះមានតែធម្មទាននេះហើយដែលមានឥទ្ធិពលគ្រប់គ្រាន់អាចកសាងធនធានមនុស្សបាន។ ធម្មទានមានន័យថា ការសំដែងធម៌ ការនិយាយធម៌ ការបង្រៀនធម៌ សេចក្តីអធិប្បាយរែកញែកនូវធម៌ការពន្យល់សេចក្តីតាមដំណើរធម៌ក្នុងគោលបំណងជួយអ្នកស្តាប់ឱ្យបានសម្រេចនូវប្រយោជន៍គឺភ្លឺច្បាស់ដោយបញ្ញាថា ធម៌នេះជាកុសល ធម៌នេះជាអកុសល ព្រមទាំងញុាំងអ្នកស្តាប់ឱ្យងាកបែរចេញពីអកុសលធម៌មកដំកល់នៅក្នុងកុសលធម៌វិញ ។

កាលបើធម្មទានដែលជាទានជួយទំនុកបម្រុងផ្នែកផ្លូវចិត្តគំនិតវិញ្ញាណនិងបញ្ញារបស់មនុស្សបានសម្រេចហើយ ប្រព្រឹត្តទៅបានស្រួលលើសង្គមមនុស្សហើយ ចូរតាំងចិត្តសង្ឃឹមចុះថាទានអ្វីៗក៏អាចកើតមានបានជាបន្តបន្ទាប់ នេះជាការពិតព្រោះថា ធម្មទានជាប្រធាននៃទានទាំងពួង បានសេចក្តីថាមនុស្សទាំងឡាយដែលនឹងធ្វើបុណ្យទៅបានក៏ព្រោះអាស្រ័យការស្តាប់ធម៌ជាហេតុ ប្រសិនបើមិនបានស្តាប់ធម៌ជាមុនទេសូម្បីតែបបរមួយបោយ បាយមួយរែក ចេកមួយស្និតក៏មិនអាចធ្វើឱ្យទៅជាទានបានឡើយ ។ គេថានៅសម័យពុទ្ធកាល គ្រប់វិស័យទាំងអស់ទាំងផ្នែកពុទ្ធចក្រក៏ដូចជាផ្នែកអាណាចក្រនៅជម្ពូទ្វីបទាំងមូលមានការចម្រើនលូតលាស់សម្បើមណាស់ ក៏ព្រោះតែអាស្រ័យធម្មទានយ៉ាងសស្រាក់សស្រាំរបស់ព្រះពុទ្ធជាម្ចាស់និងព្រះអរិយសាវ័ករបស់ព្រះអង្គជាហេតុដែរ ។

ដោយឫទ្ធានុភាពដ៏ជាក់ស្តែងរបស់ធម្មទានព្រះសម្មាសម្ពុទ្ធ បានអប់រំពួកចោរដែលបន្លំខ្លួនចូលមកអង្គុយស្តាប់ធម្មកថារបស់ព្រះអង្គឱ្យមានចិត្តជ្រះថ្លាលះបង់គំនិតខូចអាក្រក់ស្ម័គ្រចិត្តចូលបួសគ្មានសល់ម្នាក់ហើយក្រោយមកបានក្លាយជាសាវ័កដ៏ថ្លៃថ្លារបស់ព្រះពុទ្ធសាសនា បានញុាំងពួកព្រាហ្មណ៍និងពួកអន្យតិរ្ថិយ៍ជាច្រើនដែលធ្លាប់តែយល់ខុសពីដើមមកឱ្យក្លាយជាពុទ្ធបរិស័ទដ៏ប្រសើរវិញ បានស្រោចស្រង់មនុស្សឆ្កួតរិកលចរិតដើរស្រាតននលគកដូចនាងបដាចារាឱ្យក្លាយជាស្ត្រីបណ្ឌិតជាព្រះអរហន្តជាពុទ្ធសាវ័កយ៉ាងសកម្មប្រចាំនៅវត្ត

ដេតពន បានប្រោសប្រស់អង្គុលិមាលដ៏កាចសាហាវយង់ឃ្នងដែលមានដៃប្រឡាក់សុទ្ធតែឈាមឱ្យបានភាពជាព្រះអរហន្តវិញ ។

សកម្មភាពទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធដូចបានរៀបរាប់មកនេះបញ្ជាក់ឱ្យឃើញច្បាស់ថា ព្រះពុទ្ធអង្គជាអ្នកនយោបាយដ៏ឆ្នើមរកគ្មានផ្នែកខាងការប្រកាសផ្សព្វផ្សាយនិងសាបព្រោះបណ្ដុះដាំព្រះធម៌ឱ្យចាក់ឫសរីកស្គុះស្គាយត្រឈឹងត្រឈៃក្នុងលោកដោយព្រះអង្គបានយកការកសាងមនុស្សមកធ្វើជាគោលទីមួយមុនអ្វីៗទាំងអស់ ៕

ឯកសារយោង :


- ព្រះត្រៃបិដក ភាគ ១៥ ទំ.២៤៩
- ព្រះត្រៃបិដក ភាគ ២៤ ទំ.៤៣៤
- ព្រះត្រៃបិដក ភាគ ៥៧ ទំ.១៨៩
- ព្រះត្រៃបិដក ភាគ ៧៦ ទំ.១១៥
- វប្បធម៌ អរិយធម៌ ខ្មែរ-ឥណ្ឌា (ប៉ាង ខាត់)
- ពុទ្ធប្បវត្តិកថា (ឈឹម ស៊ុម)
- វប្បធម៌ពុទ្ធសាសនា (វ៉ាណ សាឌុំ)
- វប្បធម៌ អរិយធម៌ខ្មែរ (សរ សារុន)
- ពុទ្ធសាសនានិងសង្គមខ្មែរ (ធ សោ)